**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៤៦៥ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០៧

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ២០០៧

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែ ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០៣ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញក្រឹត្យលេខ៩៧ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញនាំចូល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលបានប្រកាស ឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ
- បានឃើញពិធីសារស្តីពីការអនុវត្តនាមវលី នៃតារាងពន្ធគយស៊ីចង្វាក់គ្នារបស់អាស៊ាន ដែលចុះហត្ថលេខា ដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធ និងអាករគយលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេស លើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ :** ដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ដូចមានភ្ជាប់ជាមួយនេះ ដែលបានរៀបចំដោយអនុលោមតាមប្រព័ន្ធស៊ីចង្វាក់ នៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ និងស្របទៅតាមតារាងពន្ធគយ នៃប្រព័ន្ធស៊ីចង្វាក់របស់អាស៊ាន ( AHTN 2007 )ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៧ តទៅ ។

**ប្រការ ២ :** រាល់មុខទំនិញនាំចេញ នាំចូលត្រូវជាប់ពន្ធនាំចូល អាករពិសេស អាករលើតម្លៃបន្ថែម និងអាករនាំចេញ ដូចមានចែងលំអិតក្នុងតារាងពន្ធគយនេះ ។

**ប្រការ ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ខាងមុខនេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ខេត្តក្រុង "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្ម
- ទីចាត់ការគយ និងរដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**នីចាត់ការគយនិងរដ្ឋាករ**

លេខៈ ៦៧៤ គ.រ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៧

**សូមគោរពជូន**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ:** សំណើសុំកែតម្រូវកំហុសបច្ចេកទេសមួយចំនួនលើតារាងពន្ធគយកម្ពុជាឆ្នាំ២០០៧។

**យោង:** -ប្រកាសលេខ ៨៦៥សហវ ចុះថ្ងៃទី១២ ខែមិថុនា ខែឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់តារាងពន្ធគយឆ្នាំ ២០០៧ និងលិខិតលេខ ០៣៩សហវ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសជំរាបជូនឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាបថា ក្នុងដំណើរការធ្វើសេចក្តីព្រាងតារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ដោយផ្ទេរពីតារាងពន្ធគយកម្ពុជាឆ្នាំ២០០៤ ឲ្យស្របតាមតារាងពន្ធគយសុីសង្វាក់អាស៊ានឆ្នាំ២០០៧ (AHTN 2007) នោះមានការកើតឡើងនូវកំហុសឆ្គងបច្ចេកទេស អក្ខរាវិរុទ្ធគួរឲ្យសោកស្តាយចំនួនប្រាំពីរបន្ទាត់អត្រា ដែលតម្រូវឲ្យមានការកែសំរួលឲ្យបានត្រឹមត្រូវឡើងវិញតាមបន្ទាត់អត្រា និងអត្រាពន្ធអាករជាធរមាន ដែលមានលេខកូដ និងសេចក្តីបរិយាយ ដូចខាងក្រោមនេះ :

| លេខ ទំព័រ | លេខ កូដទំនិញ | អត្រាពន្ធនិងអាករ ដែលខុស | | | | | អត្រាពន្ធនិងអាករកែតម្រូវ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | នាំចូល | | | នាំចេញ | ឯកតា | នាំចូល | | | នាំចេញ |
| | | | CD | ST | VAT | | | CD | ST | VAT | |
| 130 | 2203.00.10 | LT | 35 | 30 | 10 | 0 | KG | 35 | 20 | 10 | 0 |
| 130 | 2203.00.90 | LT | 35 | 30 | 10 | 0 | KG | 35 | 20 | 10 | 0 |
| 162 | 2707.99.20 | TNE | 7 | 10 | 10 | 0 | KG | 15 | 10 | 10 | 0 |
| 163 | 2710.11.30 | TNE | 35<br>0.02$/l | 33.33 | 10 | 0 | KG | 15 | 5 | 10 | 0 |
| 163 | 2710.11.40 | TNE | 15 | 5 | 10 | 0 | KG | 35<br>0.02$/l | 33.33 | 10 | 0 |
| 164 | 2710.19.16 | TNE | 7 | 0 | 10 | 0 | KG | 7 | 10 | 10 | 0 |
| 164 | 2710.19.79 | TNE | 15<br>0.04$/l | 4.35 | 10 | 0 | KG | 7 | 0 | 10 | 0 |

# សេចក្តីបរិយាយ

| ទំព័រ | ស្រាបៀរម៉ាលត៍ | |
|---|---|---|
| 130 | 2203.00.10 | - ស្រាបៀរពណ៌ខ្មៅ និងភេសជ្ជៈផតទ័រ |
| 130 | 2203.00.90 | - ស្រាបៀរផ្សេងទៀត រួមទាំងភេសជ្ជៈអាលេ (ភេសជ្ជៈស្រដៀងស្រាបៀរ) |
| | ផលិតផលប្រេងសិលា | |
| 162 | 2707.99.20 | - - - កាបោនខ្មៅ |
| 163 | 2710.11.30 | - - - ប្រេងសាំងក្រអូប |
| 163 | 2710.11.40 | - - - តេត្រាប្រ៉ូពីលែន |
| 164 | 2710.19.16 | - - - - ប្រេងកាត |
| 164 | 2710.19.79 | - - - - ប្រេង F.O ផ្សេងទៀត |

អាស្រ័យហេតុនេះ សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ ។

ស.ទ.ប្រតិភូរាជរដ្ឋាភិបាល

ទទួលប[illegible]ទីចាត់ការគយនិងរដ្ឋាករ

[illegible] ១

អគ្គនាយកដ្ឋានគយនិងរដ្ឋាករ

29/6/07

សៀង_ឈុនគ្រី

# វិធានទូទៅ

## វិធានទូទៅសំរាប់បកស្រាយឈ្មោះទំនិញនៅក្នុងតារាងពន្ធគយ

ការចាត់ថ្នាក់ទំនិញនៅក្នុងតារាងពន្ធគយត្រូវធ្វើឡើងដោយអនុលោមទៅតាមគោលការណ៍ដូចតទៅ :

### វិធានទី ១

ចំណងជើងរបស់ផ្នែក ជំពូក ឬជំពូករង គឺគ្រាន់តែផ្តល់ភាពងាយស្រួលសំរាប់តែចង្អុលបង្ហាញប៉ុណ្ណោះ ។ ការចាត់ថ្នាក់ត្រូវបានកំណត់ដោយស្របច្បាប់ ដោយយោងទៅតាមស័ព្ទ នៃទីតាំង និងកំណត់សំគាល់នៃផ្នែក ឬជំពូក និងវិធានដូចខាងក្រោម កាលបើទំនិញទាំងនោះ មិនផ្ទុយពីសព្ទនៃទីតាំង និងកំណត់សំគាល់នោះទេ ។

### បំណកស្រាយវិធាន ១

(I). នាមវល្លិដែលមានទំរង់ជាប្រព័ន្ធទំនិញដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្មអន្តរជាតិ ។ ទំនិញទាំងនេះ ត្រូវបានដុំនៅក្នុងផ្នែក ជំពូក និង ជំពូករង ដែលបានផ្តល់នូវចំណងជើងចង្អុលបង្ហាញយ៉ាងច្បាស់លាស់ប្រភេទនៃទំនិញ ។ ទោះជាយ៉ាងណាក៏ដោយ មានករណីជាច្រើនទំនិញប្រភេទខ្លះ និងមួយចំនួនមិនអាចចាត់ថ្នាក់នៅក្នុងផ្នែកមួយ ឬ ជំពូកមួយ ឬ យោងទៅក្នុងចំណងជើងមួយបានទេ ។

(II). ដូចនេះ វិធានទី ១ ចំណងជើងគ្រាន់តែផ្តល់ "ភាពងាយស្រួលសំរាប់ចង្អុលបង្ហាញតែប៉ុណ្ណោះ" ។ ដោយហេតុនេះ វាមិនមានលក្ខណៈស្របច្បាប់ នៃការចាត់ថ្នាក់ទេ ។

(III). ផ្នែកទីពីរនៃវិធាននេះផ្តល់ថា ការចាត់ថ្នាក់ត្រូវកំណត់ :

(ក). យោងតាមស័ព្ទនៃទីតាំង និងកំណត់សំគាល់ផ្នែក ឬជំពូកណាមួយ និង

(ខ). ដោយលក្ខណៈសមស្រប ត្រូវយោងទៅវិធានទី ២, ៣ ,៤ និង ៥ បើសិនជាមិនមានចែងនៅទីតាំងឬកំណត់សំគាល់ទាំងនេះ ។

(IV). ខដែលមានចែងនៅបំណកស្រាយ (៣ក) គឺជាការជាក់ស្តែង និងទំនិញជាច្រើនត្រូវបានចាត់ថ្នាក់នៅក្នុងនាមវល្លិដោយមិនចាំបាច់ការពិចារណាបន្ថែមលើបំណកស្រាយវិធានទេ (ឧទា. សេះរស់ (ទីតាំងលេខ ០១.០១) ទំនិញឱសថបានបញ្ជាក់ច្បាស់នៅក្នុងកំណត់សំគាល់ទី ៤ ទៅក្នុងជំពូកទី ៣០ (ទីតាំង ៣០.០៦)) ។

(V). ខដែលមានចែងនៅក្នុងបំណងស្រាយ (៣ខ) ពាក្យថា "ទីតាំងឬកំណត់សំគាល់ដែលមិនមានចែងនៅកន្លែងដទៃ" គឺមានបំណងធ្វើអោយវាកាន់តែច្បាស់ស័ព្ទនៃចំណងជើងទីតាំង និងកំណត់សំគាល់ផ្នែក ឬជំពូកដែលទាក់ទងណាមួយគឺជាការប្រសើរ មានន័យថា គេគឺ

ជាការពិចារណាលើកទីមួយនៅក្នុងការកំណត់ការចាត់ថ្នាក់ ។ ឧទាហរណ៍ នៅក្នុងជំពូកទី ៣១ កំណត់សំគាល់បានបង្ហាញថា ទីតាំងពិតប្រាកដទាក់ទងទៅនឹងទំនិញជាក់លាក់ណាមួយតែប៉ុណ្ណោះ ។ ហេតុដូចនេះហើយ ទីតាំងទាំងនេះមិនអាចពង្រីកបន្តដោយបញ្ចូលនូវទំនិញដែលអាចចាត់ថ្នាក់ផ្សេងពីនេះ ដោយហេតុផលនៃការអនុវត្តវិធានទី ២ខ ។

## វិធានទី ២

ក- សេចក្ដីយោងទាំងឡាយចំពោះវត្ថុនៅក្នុងទីតាំងមួយ គឺគបបញ្ចូលវត្ថុ ដែលមិនគ្រប់គ្រឿង ឬមិនទាន់សំរេច ឱ្យតែវត្ថុទាំងនោះ បានបង្ហាញថា មានលក្ខណៈសំខាន់អាចចាត់ជាវត្ថុគ្រប់គ្រឿង ឬវត្ថុសំរេចហើយ ។ សេចក្ដីយោងទាំងនេះ ក៏ចាត់បញ្ចូលផងដែរ ថាជាវត្ថុគ្រប់គ្រឿងឬវត្ថុសំរេច (ឬចាត់ថ្នាក់ជាវត្ថុគ្រប់គ្រឿង ឬវត្ថុសំរេច យោងតាមខ្លឹមសារវិធាននេះ)នៅពេលដែលវត្ថុទាំងនោះបានបង្ហាញក្នុងស្ថានភាពដោះជាបំណែក ឬមិនទាន់តំឡើង ។

ខ- សេចក្ដីយោងទាំងឡាយចំពោះវត្ថុធាតុ និងសារធាតុចូលក្នុងទីតាំងណាមួយ គឺវាពាក់ព័ន្ធទៅនឹងល្បាយឬបន្សំ នៃវត្ថុឬសារធាតុនោះទៅនឹងវត្ថុឬសារធាតុដទៃ ។ ដូចគ្នានេះដែរ គ្រប់និទ្ទេសនៃវត្ថុធាតុឬធាតុ ត្រូវបានបញ្ចូលទៅនឹងស្នាដៃវត្ថុនោះ ទោះបីជាបានបង្កើតពីវត្ថុធាតុនោះទាំងស្រុងឬភាគខ្លះក៏ដោយ ។ ការចាត់ថ្នាក់នៃវត្ថុល្បាយ ឬវត្ថុផ្សំទាំងនេះ ធ្វើទៅតាមគោលការណ៍ដែលចែងក្នុងវិធានទី ៣ ។

## បំណកស្រាយវិធាន ២

### បំណកស្រាយវិធានទី ២ក

### (វត្ថុគ្រប់គ្រឿង ឬមិនទាន់សំរេច)

(I)- ផ្នែកដំបូងនៃវិធានទី១ មានវិសាលភាពលើទីតាំងទាំងឡាយនៃវត្ថុជាក់លាក់ណាមួយ គឺមិនត្រឹមតែវត្ថុគ្រប់គ្រឿងប៉ុណ្ណោះទេ ក៏ប៉ុន្តែរួមទាំងវត្ថុមិនគ្រប់គ្រឿង ឬមិនទាន់សំរេចទៀតផង នៅពេលដែលវាមានលក្ខណៈពិសេសថាជាវត្ថុគ្រប់គ្រឿង ឬវត្ថុសំរេច ។

(II)- ខដែលមានចែងនៅក្នុងវិធាននេះ ក៏ត្រូវបានអនុវត្តផងដែរចំពោះ វត្ថុមិនទាន់ប្រើប្រាស់ លុះត្រាតែវាត្រូវចែងនៅក្នុងទីតាំងណាមួយច្បាស់លាស់ ។ ពាក្យ "វត្ថុមិនទាន់ប្រើប្រាស់" មានន័យថា វត្ថុមិនទាន់យកទៅប្រើប្រាស់ ហើយមានរូបរាងប្រហាក់ប្រហែល ឬទំរង់វត្ថុសំរេច ឬជាភាគ ដែលអាចយកទៅប្រើប្រាស់បានសំរាប់ការបំពេញវត្ថុសំរេច ឬភាគ លើកលែងតែករណីពិសេសមួយចំនួន ។

ផលិតផលពាក់កណ្តាលសំរេចមិនទាន់មានរូបរាងសំខាន់របស់វត្ថុសំរេច(ដូចជាដុំដែកមានរាងទ្រវែង, រង្វង់, បំពង់ ។ល។ មិនត្រូវបានចាត់ថាជា"វត្ថុមិនទាន់ប្រើប្រាស់"ទេ ។

(III)- ដោយឃើញថា ទំហំនៃទីតាំងទាំងឡាយនៃផ្នែក I ទៅ IV ផ្នែកនៃវិធាននេះ មិនត្រូវបានអនុវត្តជាទូទៅចំពោះទំនិញនៅក្នុងផ្នែកទាំងឡាយនេះ ។

(IV)- មានករណីជាច្រើននៅក្នុងវិធាន ត្រូវបានរៀបរាប់នៅក្នុងកំណត់សំគាល់នៃបំណកស្រាយទូទៅរបស់ផ្នែក ឬជំពូក (ឧទាហរណ៍ ផ្នែកទី XVI ឬ ជំពូក ៦១, ៦២, ៨៦, ៨៧ និង ៩០) ។

**បំណកស្រាយវិធានទី ២ក**

**(វត្ថុដែលមិនទាន់តំឡើង ឬដោះជាបំណែក)**

(V)- ផ្នែកទីពីរនៃវិធានទី ២ក បដិញ្ញតឬចែងថា វត្ថុគ្រប់គ្រឿងឬវត្ថុសំរេច ដែលបង្ហាញថា មិនទាន់តំឡើងឬដោះជាបំណែក ត្រូវបានចាត់ថ្នាក់ដូចទីតាំងរបស់វត្ថុដែលតំឡើងរួច ។ ពេលដែលទំនិញមកជាមួយភាពមានមុខងារសំរាប់ខ្ចប់, លើកដាក់ ឬសំរាប់ដឹកជញ្ជូន ។

(VI)- វិធាននេះក៏អនុវត្តផងដែរចំពោះវត្ថុមិនគ្រប់គ្រឿង ឬមិនទាន់សំរេច ដែលនៅជាមិនទាន់តំឡើងឬដោះជាបំណែក ត្រូវបានចាត់ដូចវត្ថុគ្រប់គ្រឿងឬសំរេច ដោយយោងតាមលក្ខណៈ ផ្នែកដំបូង នៃវិធាននេះ ។

(VII)- តាមអត្ថន័យនៃវិធាននេះ "វត្ថុដែលមិនទាន់តំឡើង ឬដោះជាបំណែក" មានន័យថា វត្ថុដែលសមាសភាគត្រូវបានតំឡើងដោយគ្រឿងឬឧបករណ៍សាមញ្ញ ឧទាហរណ៍ ទួណឺវីស, ក្បាលឡោស៊ី ប៊ូឡុង...។ល។ ឬដោយមីននិងផ្សារ ។ សមាសភាគនៃវត្ថុមិនទាន់តំឡើងដែលលើសពីតំរូវការប្រើប្រាស់ត្រូវចាត់ថ្នាក់ក្នុងទីតាំងផងដែរ ។

(VIII)- ករណីមួយចំនួននៅក្នុងវិធាន ត្រូវបានចែងក្នុងកំណត់សំគាល់នៃបំណកស្រាយទូទៅរបស់ផ្នែក ឬជំពូក (ឧទាហរណ៍ ផ្នែកទី XVI និងជំពូកទី ៨៤, ៨៦, ៨៧ និង ៨៩)

(IX)- ដោយឃើញថា ទំហំនៃទីតាំងទាំងឡាយនៃផ្នែក I ទៅ IV ផ្នែកនៃវិធាននេះ មិនត្រូវបានអនុវត្តជាទូទៅចំពោះទំនិញនៅក្នុងផ្នែកទាំងឡាយនេះ ។

**បំណកស្រាយវិធានទី ២ខ**

**(ល្បាយ និងសមាសធាតុផ្សំ ឬសារធាតុ)**

(X)- វិធានទី ២ខ ចែងអំពីល្បាយ និងសមាសធាតុផ្សំ ឬសារធាតុនៃទំនិញដែលមានពីរ ឬច្រើនសារធាតុ ឬសមាសធាតុ ។ ទីតាំងដែលមានសារធាតុ ឬសមាសធាតុនៅក្នុងទីតាំងតែម្តង ដូចជាទីតាំងលេខ ០៤.០៣ (សក់សេះ) និង ៤៥.០៣ (វត្ថុបានមកពីឈើក្រកធម្មជាតិ)។

ចូរកត់សំគាល់ថា វិធាននេះក៏អនុវត្តផងដែរ ប្រសិនបើកំណត់សំគាល់ទីតាំង ឬផ្នែក ឬជំពូក មិនមានចែងនៅកន្លែងផងៃ ឧទា.ទីតាំងលេខ ១៥.០៣ ខ្លាញ់ជ្រូក, មិន..លាយ។ ល្បាយបានរៀបចំជាស្រេចដូចមានចែងក្នុងអត្ថបទនៃកំណត់សំគាល់ផ្នែកឬជំពូក ឬទីតាំងត្រូវបានចាត់ថ្នាក់ដោយអនុលោមទៅតាមវិធានទី ១ ។

(XI).ការអនុវត្តវិធាននេះ ដើម្បីពង្រីកនូវការយោងទាំងឡាយរបស់សារធាតុ ឬសមាសធាតុចំពោះទីតាំងដោយធ្វើការរួមបញ្ចូលល្បាយ ឬការលាយចូលគ្នាជាមួយសាធាតុ ឬសមាសធាតុផ្សេងទៀត។ វិធានក៏អនុវត្តផងដែរចំពោះទំនិញដែលមានតែមួយផ្នែករបស់សារធាតុ ឬសមាសធាតុ ។

(XII). ទោះជាយ៉ាងណាក៏ដោយ វិធាននេះ មិនអាចពង្រីកទីតាំងគ្របដណ្តប់ទំនិញដែលមិនមានចែងនៅក្នុងវិធានទី១ទេ ក្នុងការឆ្លើយតបទៅនឹងការបរិយាយនៃទីតាំង។ វាអនុវត្តតែនៅពេលណាមានបន្ថែមវត្ថុធាតុ ឬសារធាតុផ្សេងទៀត បង្ខូចនូវលក្ខណៈទំនិញនៃប្រភេទទំនិញដែលបានលើកឡើងនៅក្នុងទីតាំង ។

(XIII).ជាផលវិបាកនៃវិធាននេះ ល្បាយ ឬការលាយចូលគ្នានិងទំនិញដែលមានសំការៈ ឬសារធាតុច្រើនបញ្ចូលគ្នា ត្រូវតែចាត់ថ្នាក់ដោយយោងទៅតាមគោលការណ៍នៃវិធានទី ៣ បើសិនជាទំនិញនោះអាចចាត់ថ្នាក់នៅក្នុងទីតាំងពីរ ឬច្រើន ។

## វិធានទី ៣

ប្រសិនជាទំនិញឃើញដូចជាត្រូវចាត់ថ្នាក់មានពីរទីតាំង ឬក៏ច្រើនទីតាំងដោយអនុវត្តតាមវិធានទី ២ខ ឬដោយហេតុផលផ្សេងនោះ ការចាត់ថ្នាក់នឹងធ្វើដូចតទៅនេះ :

ក- ទីតាំងណាដែលសមស្របបំផុតត្រូវមានអាទិភាពលើបណ្តាទីតាំងដែលមានន័យទូទៅ ។ ក៏ប៉ុន្តែ កាលបើមានពីរឬច្រើនទីតាំងហើយទីតាំងនីមួយៗពាក់ពន្ធ័ទៅតែមួយភាគប៉ុណ្ណោះ នៃវត្ថុធាតុដែលបង្កើតជាផលិតផលល្បាយណាមួយ ឬវត្ថុផ្សំណាមួយ ឬតែភាគណាមួយ នៃវត្ថុ នៅក្នុងករណីដែលទំនិញបង្ហាញជាសម្រាប់ដើម្បីលក់រាយ ទីតាំងចំពោះផលិតផល ឬវត្ថុទាំងនោះ ត្រូវចាត់ទុកជាពិសេសថាស្មើគ្នា ទោះបីជាទំនិញណាមួយពណ៌នាច្បាស់លាស់ ឬ ពេញលេញជាងក៏ដោយ ។

ខ- ផលិតផលល្បាយ វត្ថុដែលផ្សំដោយវត្ថុធាតុខុសគ្នា ឬក៏បង្កើតឡើងដោយសមាសធាតុផ្សេងៗគ្នា និងទំនិញបង្ហាញជាសម្រាប់ហើយខ្ចប់សំរាប់លក់រាយ ដែលការចាត់ថ្នាក់មិនអាចអនុវត្តតាមវិធានទី ៣ក ខាងលើនេះត្រូវចាត់ថ្នាក់ទៅតាមវត្ថុធាតុ ឬវត្ថុណាមួយដោយដែលមានលក្ខណៈសំខាន់ជាង កាលបើលក្ខណៈវិនិច្ឆ័យនេះ អាចអនុវត្តទៅបាន ។

គ- ក្នុងករណីដែលវិធានទី ៣ក និង ៣ខ មិនអនុញ្ញាតឱ្យធ្វើការចាត់ថ្នាក់បានទេនោះ ទំនិញត្រូវចាត់ថ្នាក់ទៅក្នុងទីតាំងមួយ ដែលនៅក្រោយបំផុតទៅតាមលេខលំដាប់ក្នុងចំណោមទីតាំងដែលយកជាបានការ ។

## បំណកស្រាយវិធាន ៣

(I). វិធាននេះផ្តល់វិធីសាស្ត្របីសំរាប់ការចាត់ថ្នាក់មុខទំនិញ (ដែលឃើញជាលើកដំបូង) ដែលអាចនៅក្នុងទីតាំងពីរ ឬច្រើនស្ថិតនៅក្រោមសំណួនៃវិធានទី ២ខ ផង ឬសំរាប់ហេតុផលផ្សេងណាមួយផង ។ វិធីសាស្ត្រទាំងនេះ អនុវត្តតាមលំដាប់ដូចដែលបានដាក់ចេញនៅក្នុងវិធាន ។ ដូចនេះ វិធានទី ៣ខ អនុវត្តបានលុះត្រាតែវិធាន ៣ក មិនអាចធ្វើការចាត់ថ្នាក់បាន ហើយប្រសិនបើវិធាន ៣ក និង ៣ខ មិនអាចអនុវត្តបានត្រូវប្រើវិធានទី ៣គ ។ លំដាប់ដែលមានអាទិភាព គឺ (ក). បរិយាយជាក់លាក់, (ខ). លក្ខណៈសំខាន់, (គ). ទីតាំងដែលមានលំដាប់លេខចុងក្រោយ ។

(II). វិធានដែលមានប្រសិទ្ធិភាព គឺសំរាប់តែកំណត់សំគាល់ទីតាំង ឬផ្នែក ឬជំពូក ដែលមិនមានចែងនៅកន្លែងដទៃ ។ ឧទាហរណ៍ កំណត់សំគាល់ ៤ខ នៃ ជំពូកទី ៩៧ តំរូវទំនិញដែលមានការបរិយាយទាំងនៅក្នុងទីតាំងមួយពី ៩៧.០១ ដល់ ៩៧.០៥ និងដែលមានការបរិយាយទាំងនៅក្នុងទីតាំងលេខ ៩៧.០៦ ត្រូវចាត់ថ្នាក់នៅក្នុងទីតាំងមុនដំបូង ។ ទំនិញទាំងនេះ ត្រូវចាត់ថ្នាក់យោងតាមកំណត់សំគាល់ ៤ខ នៃជំពូកទី ៩៧ និង មិនយោងទៅនឹងវិធាននេះទេ ។

## បំណកស្រាយវិធាន ៣ក

(III). វិធីសាស្ត្រទី ១ នៃការចាត់ថ្នាក់ដែលមាននៅក្នុងវិធានទី ៣ក គឺផ្តល់នូវការបរិយាយមុខទំនិញយ៉ាងជាក់លាក់បំផុតជាងទីតាំងដែលមានការបរិយាយទូទៅ ។

(IV). វាមិនអាចអនុវត្តបាននូវការដាក់ចេញវិធានដ៏តឹងរឹង និងការពន្យល់លឿនពេកសំរាប់ការកំណត់ថា ទីតាំងមួយបរិយាយពិសេសជាងទីតាំងផ្សេងនោះឡើយ ប៉ុន្តែ ជាទូទៅអាចនិយាយបានថា:

(ក).ការបរិយាយតាមឈ្មោះមានភាពជាក់ច្បាស់ជាងតាមប្រភេទ (ឧទាហរណ៍ ប្រដាប់កោរពុកមាត់ និងកន្ត្រៃកាត់សក់ប្រើដោយម៉ូទ័រអគ្គិសនី ត្រូវចាត់ថ្នាក់ក្នុងទីតាំងលេខ ៨៥.១០ និង ៨៥.០៨ ជាឧបករណ៍មេកានិកប្រើអគ្គិសនី សំរាប់ការប្រើដោយដៃ ឬក្នុងទីតាំងលេខ ៨៥.០៩ សំរាប់ឧបករណ៍មេកានិកប្រើអគ្គិសនីមានម៉ូទ័រប្រើក្នុងផ្ទះ)។

(ខ). បើសិនជាទំនិញត្រូវនឹងការបរិយាយដែលបញ្ជាក់ច្បាស់លាស់អំពីខ្លួនវា នោះការបរិយាយនោះគឺមានភាពជាក់ច្បាស់ជាងការ បរិយាយណាដែលមានការបញ្ជាក់មិនមានភាពពេញលេញ ។

ឧទាហរណ៍ប្រភេទទំនិញខាងក្រោម :

(១). ព្រំធ្វើពីក្រណាត់ត្បាញមានរាងកញ្ចុំ ព្រំនេះសំរាប់ប្រើក្នុងរថយន្ត វាមិនត្រូវចាត់ថ្នាក់ជាបរិក្ខារបន្សំរបស់រថយន្តនៅក្នុងទីតាំងលេខ ៨៧.០៨ ទេ តែវាត្រូវចាត់ថ្នាក់ចូលទៅក្នុងទីតាំងលេខ ៥៧.០៣ ព្រោះវាត្រូវបានបញ្ជាក់ច្បាស់ជាងថាវាជាព្រំ ។

(២). កញ្ចក់ការពារដែលគ្មានគ្រោងរួមមានការធ្វើឱ្យស៊ិត ឬបិតភ្ជាប់គ្នាកាត់ជារាងសំរាប់ប្រើប្រាស់ក្នុងយន្តហោះ ដែលមិនត្រូវចាត់ថ្នាក់ដោយថាជាបំណែកនៃទំនិញនៅក្នុងទីតាំងលេខ ៨៨.០១ ឬ ៨៨.០២ ទេ ប៉ុន្តែនៅក្នុងទីតាំងលេខ ៧០.០៧ នៅពេលដែលវាត្រូវបានបញ្ជាក់ច្បាស់ថែមទៀតថា វាជាកញ្ចក់សំរាប់ការពារ ។

(V). ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលទីតាំងពីរ ឬច្រើនដែលមួយៗមានតែបំណែក ឬភាគតែពីរនៃសំភារៈ ឬសាធាតុ ដែលមាននៅក្នុងទំនិញល្បាយឬសមាសធាតុណាមួយនោះ ឬមានតែបំណែកឬភាគតែប៉ុណ្ណោះនៃវត្ថុដែលរៀបចំសំរាប់លក់រាយនោះ ទីតាំងទាំងនោះ ត្រូវចាត់ថា មានលក្ខណៈស្មើគ្នាទាក់ទងទៅនឹងទំនិញនោះ ទោះបីជាទីតាំងមួយក្នុងចំណោមទីតាំងទាំងនោះផ្តល់នូវការបរិយាយពេញលេញ ឬជាក់ច្បាស់ជាងក៏ដោយ ។ ក្នុងករណីនេះ វិធាន ៣ខ ឬ ៣គ ត្រូវប្រើសំរាប់កំណត់នូវចំណាត់ថ្នាក់ទំនិញទាំងនោះ។

**បំណកស្រាយវិធាន ៣ខ**

(VI). វិធីសាស្ត្រទីពីរនេះទាក់ទងតែជាមួយ :

(១). ផលិតផលល្បាយ

(២). ទំនិញល្បាយដែលរួមមានសំភារៈផ្សេងគ្នា

(៣). ទំនិញល្បាយដែលរួមមានសមាសភាគផ្សំផ្សេងគ្នា

(៤). ទំនិញជាសម្រាប់រៀបចំសំរាប់លក់រាយ

វិធាននេះអនុវត្តទៅបានលុះត្រាតែវិធាន ៣ក មិនអាចអនុវត្តបាន ។

(VII). ក្នុងករណីទាំងនេះទំនិញ ត្រូវបានចាត់ថ្នាក់នៅពេលដែលវាត្រូវធ្វើឡើងដោយវត្ថុធាតុ ឬសមាសភាគដែលបង្ហាញពីលក្ខណៈសំខាន់របស់វា បើលក្ខណៈនេះអាចអនុវត្តបាន ។

(VIII). កត្តាដែលអាចអោយកំណត់បាននូវលក្ខណៈសំខាន់ អាចប្រែប្រួលទៅតាមប្រភេទ នៃទំនិញ ។ ឧទាហរណ៍ វាត្រូវបានកំណត់ដោយលក្ខណៈធម្មជាតិនៃវត្ថុធាតុ ឬសមាសភាគ

តាមរយៈលក្ខណៈចាក់ធារ បរិមាណ ទម្ងន់ ឬតំលៃ ឬតាមរយៈតួនាទីរបស់វត្ថុធាតុចំបង ដែលទាក់ទងទៅនឹងការប្រើប្រាស់នៃទំនិញ។

(IX). គោលបំណងនៃវិធាននេះ ទំនិញល្បាយដែលធ្វើឡើងដោយសមាសភាគផ្សេងៗ មិនគ្រាន់តែមានសមាសភាគដែលភ្ជាប់មកជាមួយគ្នាមួយដើម្បីផ្គុំឱ្យបានជាទំនិញទាំងស្រុង នោះទេ ទោះជាដាច់គ្នាក៏ដោយ សមាសធាតុទាំងនេះ ទទួលស្គាល់ថាជាផ្នែកមួយ និងអាចប្រើបំពេញអោយគ្នាទៅវិញទៅមក ហើយផ្នែកទាំងអស់នោះត្រូវប្រើសំរាប់បង្កើតឱ្យបាននូវទំនិញទាំងស្រុងមួយ ដែលទំនិញនោះមិនអាចដាក់លក់ជាបំណែកៗបានដាច់ពីគ្នាបានឡើយ ។

ឧទាហរណ៍ទំនិញដូចខាងក្រោម :

(១).ចានកន្ទុយបារីដែលរួមមានជើងទម្រ ដែលអាចដោះយកចានចេញពីជើងទម្របាន ។

(២).ធ្នើដាក់ដាក់គ្រឿងទេសសំរាប់ប្រើក្នុងផ្ទះ ដែលមានគ្រោងរចនាបថជាពិសេស (ធម្មតាធ្វើពីឈើ) និងមានរូបរាង និងទំហំសមល្មមសំរាប់ក្រឡទេសសំរាប់ដាក់គ្រឿងទេស ។

ដូចនៅក្នុងវិធានទូទៅ សមាសភាគនៃទំនិញល្បាយនោះត្រូវតែដាក់ក្នុងកញ្ចប់រួមមួយ ។

(X). ចំពោះវិធាននេះ ពាក្យថា "ទំនិញរៀបចំសំរាប់លក់រាយ" មានន័យថា ទំនិញទាំងឡាយណាដែល :

ក. រួមមានយ៉ាងតិចវត្ថុធាតុពីរផ្សេងគ្នា ដែលអាចចាត់ថ្នាក់ក្នុងទីតាំងពីរផ្សេងគ្នា ។ ដូចនេះតាមខ្លឹមសារនៃវិធាននេះ ជាឧទាហរណ៍ សមសំរាប់ហូនខ្វចំនួន ៦ មិនអាចចាត់ថាជាទំនិញជាសម្រាប់បានទេ។

ខ. រួមមានផលិតផល ឬវត្ថុធាតុដែលដាក់បញ្ចូលគ្នាបដើម្បីឆ្លើយតបនឹងតម្រូវការជាក់លាក់ណាមួយ ឬអនុវត្តនូវសកម្មភាពជាក់លាក់ណាមួយ និង

គ. ដាក់បញ្ចូលគ្នា សមស្របសំរាប់លក់ជូនអ្នកប្រើប្រាស់ដោយផ្ទាល់ ដោយគ្មានការវេចខ្ចប់ឡើងវិញទេ (ដូចជាដាក់ក្នុងប្រអប់ ឡាំង ឬកិសជាដើម)។

ដូចនេះ ពាក្យនេះគ្របដណ្តប់ ជាឧទាហរណ៍ ចំពោះទំនិញមួយសម្រាប់ដែលរួមមានគ្រឿងអាហារផ្សេងៗសំរាប់ប្រើជាមួយនឹងគ្រឿងម្ហូបដែលគេចំអិនហើយ ។

ឧទាហរណ៍ សំរាប់ទំនិញមួយសម្រាប់ ដែលអាចចាត់ថ្នាក់បានដោយយោងទៅលើវិធានទី៣ខ មានដូចតទៅ :

(១) ក. ទំនិញមួយសម្រាប់ រួមមានសាំងវិចសាច់គោ ទោះមានឬគ្មានប្រូម៉ាហ្ស ដាក់ក្នុងប្រអប់ នៃទីតាំងលេខ ១០.០២ វេចជាមួយចំណិតដំឡូងបារាំង (French fries) នៃទីតាំងលេខ ២០.០៤ :

ការចាត់ថ្នាក់ត្រូវនៅទីតាំងលេខ ១៦.០២ ។

ខ.ទំនិញមួយវត្ថុជាសម្រាប់ សមាសភាគរបស់វាត្រូវបានប្រើប្រាស់ជាមួយគ្នានៅក្នុងការរៀបចំអាហារស្ពាហ្គេទី រួមមានកញ្ចប់នៃស្ពាហ្គេទីមិនទាន់ចំអិន (ទីតាំងលេខ ១៩.០២) កញ្ចប់តូចៗនៃប្រូម៉ាហ្ស (ទីតាំងលេខ ០៤.០៦) និងកំប៉ុងតូចៗ នៃទឹកជ្រលក់ប៉េងប៉ោះ (ទីតាំងលេខ ២១.០៣) ដាក់នៅក្នុងប្រអប់កាតុង :

ការចាត់ថ្នាក់ ត្រូវនៅក្នុងទីតាំងលេខ ១៩.០២ ។

ទោះជាយ៉ាងណាក៏ដោយ វិធាននេះមិនរាប់បញ្ចូលផលិតផលមួយចំនួន ដែលដាក់បញ្ចូលគ្នា ឧទាហរណ៍:

- ព្រោនមួយកំប៉ុង(ទីតាំងលេខ ១៦.០៥) ប៉ាតេថ្លើមមួយកំប៉ុង Paté de foie (ទីតាំងលេខ ១៦.០២) ប្រូម៉ាហ្សមួយកំប៉ុង (ទីតាំងលេខ ០៤.០៦) សាច់បីជាន់ស្តើងៗមួយកំប៉ុង (ទីតាំងលេខ ១៦.០២) និងសាច់ក្រកគុំតែមួយកំប៉ុង (ទីតាំងលេខ ១៦.០១)ឬ
- គ្រឿងស្រវឹងមួយដបទីតាំងលេខ ២២.០៨ និងស្រាមួយដបនៃទីតាំងលេខ ២២.០៤ ។

ករណីនៃឧទាហរណ៍ទាំងពីរខាងលើ និងផលិតផលប្រហាក់ប្រហែលគ្នាមួយចំនួន មុខទំនិញនីមួយៗ ត្រូវចាត់ថ្នាក់ដាច់ៗពីគ្នាទៅតាមទីតាំងសមស្របរបស់ខ្លួន ។

(២). គ្រឿងធ្វើសក់មួយសម្រាប់ រួមមានគុងទីអគ្គិសនីមួយ (ទីតាំងលេខ ៨៥.១០) ក្រាសសិតសក់មួយ (ទីតាំងលេខ ៩៦.០៣) កន្ត្រៃមួយ (ទីតាំងលេខ ៨២.១៣) ច្រាសមួយ (ទីតាំងលេខ ៩៦.០៣) និងកន្សែងពោះគោមួយ (ទីតាំងលេខ ៦៣.០២) ដាក់នៅក្នុងប្រអប់ស្បែកមួយ (ទីតាំងលេខ ៤២.០២) ។

ការចាត់ថ្នាក់ ត្រូវនៅក្នុងទីតាំងលេខ ៨៥.១០ ។

(៣). ឧបករណ៍សំរាប់គូរមួយប្រដាប់ មានបន្ទាត់មួយ (ទីតាំងលេខ ៩០.១៧), ម៉ាស៊ីនគណនាជាថាសមួយ (ទីតាំងលេខ ៩០.១៧), ដែកឈានមួយ (ទីតាំងលេខ ៩០.១៧), ខ្មៅដៃមួយ (ទីតាំងលេខ ៩៦.០៩) និងប្រដាប់ចិតខ្មៅដៃមួយ (ទីតាំងលេខ ៨២.១៤) ដាក់នៅក្នុងប្រអប់ផ្លាស្ទិកស្តើងមួយ (ទីតាំងលេខ ៤២.០២) ។

ការចាត់ថ្នាក់ ត្រូវនៅក្នុងទីតាំងលេខ ៩០.១៧ ។

ចំពោះវត្ថុជាសម្រាប់ដូចបានលើកឡើងខាងលើ ការចាត់ថ្នាក់ត្រូវបានធ្វើឡើងយោងទៅតាមសមាសភាគ ឬសមាសភាគផ្សំចូលគ្នា ដែលអាចត្រូវបានស្គាល់ថាសម្រាប់ទាំងមូលដែលមានលក្ខណៈសំខាន់ ។

(XI). វិធាននេះ មិនអាចអនុវត្តលើទំនិញដែលខ្ចប់ដាច់ៗពីគ្នាដាក់នៅជាមួយគ្នា ទោះជានៅ ឬមិននៅក្នុងកញ្ចប់តែមួយក៏ដោយ ឧទាហរណ៍ភេសជ្ជៈ (មានសមាមាត្រថេរមួយ នៃឧស្សាហកម្មផលិតភេសជ្ជៈ) ។

**ចំណារស្រាយវិធានទី ៣គ**

(XII). នៅពេលដែលទំនិញមិនអាចចាត់ថ្នាក់បានតាមវិធានទី ៣ក ឬ ៣ខ ទំនិញទាំងនេះត្រូវចាត់ថ្នាក់នៅក្នុងទីតាំងមានលំដាប់លេខចុងក្រោយ ក្នុងចំណោមទំនិញដែលមានគុណសម្បត្តិស្មើគ្នាសំរាប់ការកំណត់ការចាត់ថ្នាក់នេះ ។

## វិធានទី ៤

បណ្តាទំនិញដែលមិនអាចចាត់ថ្នាក់បានទៅតាមគោលការណ៍ខាងលើនេះ ត្រូវចាត់ថ្នាក់ទៅក្នុងទីតាំងពាក់ព័ន្ធនឹងវត្ថុដែលមានភាពប្រហាក់ប្រហែលបំផុត ។

**ចំណារស្រាយវិធានទី ៤**

(I). វិធាននេះ ទាក់ទងទៅនឹងទំនិញដែលមិនធ្វើការចាត់ថ្នាក់តាមវិធានទី ១ ដល់ ៣ ។ វិធាននេះ បញ្ជាក់ថាទំនិញបែបនោះត្រូវធ្វើការចាត់ថ្នាក់ទៅទីតាំងសមស្របដែលជាទំនិញប្រហាក់ប្រហែលបំផុត ។

(II). នៅក្នុងការចាត់ថ្នាក់ក្នុងវិធានទី៤ វាជាការចាំបាច់ដើម្បីប្រៀបធៀបទំនិញនេះមួយទៅនឹងទំនិញប្រហាក់ប្រហែល ដើម្បីធ្វើការកំណត់លេខសំគាល់ទំនិញនេះ ។ ទំនិញនេះត្រូវចាត់ថ្នាក់ទៅក្នុងទីតាំងដូចគ្នានឹងទំនិញប្រហាក់ប្រហែលបំផុត ។

(III). ជាការពិត ភាពប្រហាក់ប្រហែល គឺផ្អែកលើកត្តាជាច្រើន ដូចជាការបរិយាយលក្ខណៈ និងគោលបំណង ។

## វិធានទី ៥

ក្រៅពីបទបញ្ញត្តិខាងលើនេះ វិធានតទៅនេះ ត្រូវតែអនុវត្តទៅលើទំនិញដែលចែកដូចខាងក្រោម :

ក- ស្រោមបរិធានថតរូប ស្រោមសំរាប់ឧបករណ៍ភ្លេង កិសដាក់អាវុធ ហិបដាក់ប្រដាប់ប្រដាជាងគំនូរ ប្រអប់ (ដាក់មាសប្រាក់) និងប្រដាប់ប្រហាក់ប្រហែលពិសេសសំរាប់ដាក់វត្ថុនោះ កាលបើស្រោមប្រអប់ទាំងនោះ វាជាប្រភេទធម្មតាសំរាប់លក់ជាមួយឧបករណ៍ទាំង

នោះ ត្រូវបានចាត់ថ្នាក់ទៅតាមវត្ថុទាំងនោះ ។ ប៉ុន្តែ បទបញ្ញត្តិនេះ មិនអនុវត្តឡើយចំពោះស្រោមសំបកទាំងឡាយណាដែលសំរាប់ថែរក្សាលក្ខណៈសំខាន់នៃវត្ថុ ។

ខ- លើកលែងតែបទបញ្ញត្តិនៃវិធាន ៥ក ខាងលើនេះ សំបកវេចខ្ចប់ដែលក្នុងនោះមានដាក់ទំនិញត្រូវចាត់ថ្នាក់ជាមួយទំនិញទាំងនោះកាលបើវាសំរាប់ប្រើជាធម្មតាសំរាប់ទំនិញនោះ ។ ប៉ុន្តែបញ្ញត្តិនេះ មិនអនុវត្តទេកាលបើសំបកវេចខ្ចប់នោះដែលអាចយកទៅប្រើប្រាស់បានជាច្រើនដងទៅទៀត ។

**បំណកស្រាយវិធានទី ៥ក**

**(កេស ប្រអប់ និង ស្រោមសំបកប្រហាក់ប្រហែល)**

(I). វិធាននេះ គួររាប់បញ្ចូលតែសំបកទាំងឡាយណាដែល :

(១). ដែលត្រូវបានធ្វើជារាងពិសេស ឬតំឡើងសំរាប់ដាក់ឬផ្ទុកវត្ថុជាក់លាក់ណាមួយ ឬមួយសម្រាប់នៃវត្ថុ មានន័យថា ស្រោមសំបកវេចខ្ចប់ ត្រូវបានគេគ្រោងឡើងជាពិសេសឱ្យស្របទៅនឹងវត្ថុដែលគេមានបំណងដាក់ឬផ្ទុក ។ ស្រោមសំបកមួយចំនួនត្រូវបានគេធ្វើជារាងតាមទំរង់ដែលគេដែលគេចង់ដាក់ឬផ្ទុក ។

(២). សមស្របសំរាប់ការប្រើប្រាស់យូរអង្វែង មានន័យថា គេគ្រោងឡើងដើម្បីអោយមានរយៈពេលយូរអាចប្រៀបធៀបទៅនឹងវត្ថុដែលគេចង់ដាក់ឬផ្ទុកនោះ ។ សំបកទាំងនេះប្រើប្រាស់ផងដែរ សំរាប់ការពារវត្ថុនៅពេលដែលមិនទាន់ប្រើប្រាស់(ឧទាហរណ៍ ក្នុងកំឡុងពេលដឹកជញ្ជូន ស្តុកទុក ឬរក្សាទុក)។ លក្ខណៈស្រោមសំបកទាំងនេះខុសពីលក្ខណៈនៃស្រោមសំបកធម្មតា ។

(៣). សំរាប់ដាក់ឬផ្ទុកវត្ថុ ទោះជាវត្ថុទាំងនោះ ត្រូវវេចខ្ចប់ដាច់ដោយឡែកពីសំបកដើម្បីងាយស្រួលដល់ការដឹកជញ្ជូនក៏ដោយ ។ ស្រោមសំបក ដែលនៅដាច់ដោយឡែកពីទំនិញ ត្រូវចាត់ថ្នាក់តាមទីតាំងសមស្របរបស់វា ។

(៤). គឺជាប្រភេទជាទូទៅលក់ជាមួយវត្ថុនោះ និង

(៥). មិនផ្តល់លក្ខណៈពិសេសរបស់វាទាំងមូល ។

(III). ឧទាហរណ៍ នៃស្រោមសំបក នាំមកជាមួយវត្ថុដែលត្រូវដាក់ឬផ្ទុក ត្រូវចាត់ថ្នាក់ដោយយោងតាមវិធាននេះ គឺ :

(១). ប្រអប់ និង ហិបគ្រឿងអង្ការ (ទីតាំងលេខ ៧១.១៣)

(២). ប្រអប់ដាក់ប្រដាប់កោរពុកមាត់អគ្គិសនី (ទីតាំងលេខ ៨៥.១០)

(៣). ប្រអប់កែវយឺត ប្រអប់កែវពង្រីក (ទីតាំងលេខ ៩០.០៥)

(៨). ប្រអប់ដាក់ឧបករណ៍តន្ត្រី ប្រអប់ និងថង់ (ឧទា. ទីតាំងលេខ ៩០.០២)

(៩). កិសកាំភ្លើង (ឧទា. ទីតាំងលេខ ៩០.០៣)

(III). ឧទាហរណ៍ នៃស្រោមសំបកមិនរាប់បញ្ចូលក្នុងវិធាននេះ គឺជាសំបកដូចជាកញ្ចប់តែ មានដាក់តែ ឬធានសោភមិកសំរាប់គុបតែងលំអមានស្គគ្រាប់ក្នុងនោះ ។

**បំណកស្រាយវិធានទី ៥ខ**

**(សំភារៈវេចខ្ចប់ និងសំបកវេចខ្ចប់)**

(IV). វិធាននេះ គ្រប់គ្រងការចាត់ថ្នាក់នៃសំភារៈវេចខ្ចប់ និងសំបកវេចខ្ចប់ នៃប្រភេទមួយ ដែលជាទូទៅត្រូវបានប្រើប្រាស់សំរាប់វេចខ្ចប់ទំនិញដែលពាក់ព័ន្ធ ។ ទោះជាយ៉ាង ណាក៏ដោយ បទបញ្ញាតិនេះ មិនចងនៅពេលដែលសំភារៈវេចខ្ចប់ឬសំបកវេចខ្ចប់ បែបនេះ គឺបញ្ជាក់ច្បាស់ថាសមស្រប សំរាប់ការប្រើប្រាស់ដដែលៗ ឧទាហរណ៍ ធុងដែក ឬ សំបកធ្វើពីដែកថែបឬដែកស្និតសំរាប់ដាក់ឧស្ម័ន ។

(V). វិធាននេះ គឺយោងតាមវិធានវិធីទី ៥ក ដូចនេះការចាត់ថ្នាក់កិសឬហិប ប្រអប់ និង ស្រោមសំបកប្រហាក់ប្រហែល នៃប្រភេទដែលបានលើកឡើងនៅក្នុង វិធាន ៥ក ត្រូវកំណត់ ដោយការអនុវត្តន៍នៃវិធាននោះ ។

## វិធានទី ៦

សំរាប់គោលបំណងស្របច្បាប់ ការចាត់ថ្នាក់ទំនិញចូលក្នុងទីតាំងរង នៃទីតាំងដូចគ្នា ត្រូវ កំណត់ទៅតាមសព្ទ នៃទីតាំងរងទាំងនោះ និងតាមកំណត់សំគាល់ឬកំណត់សំគាល់ ដែលពាក់ ព័ន្ធ និង (បើមានការចាំបាច់) ទៅតាមវិធានខាងលើ ហើយសូមបញ្ជាក់ថា អាចប្រៀប ធៀបគ្នាបាន ចំពោះតែវត្ថុដែលស្ថិតនៅក្នុងទីតាំងរងដែលមានកំរិតដូចគ្នា ។ គោលបំណងនៃ វិធាននេះ បណ្តាកំណត់សំគាល់នៃផ្នែកនីមួយៗ និងជំពូកនីមួយៗ ត្រូវអនុវត្តផងដែរ លើក លែងតែមានបទបញ្ញត្តិផ្ទុយគ្នា ។

**បំណកស្រាយវិធានទី ៦**

(I). វិធានទី ១ ដល់ ៥ (បើមានការចាំបាច់) ខាងលើសំរាប់អនុវត្តចំពោះការចាត់ថ្នាក់លើ កំរិតទីតាំងរងជាមួយ និងទីតាំងនោះ ។

(II). គោលបំណងនៃវិធានទី៦ ឃ្លាប្រយោគខាងក្រោមមានន័យសំរាប់អ្វីដែលបានកំណត់ថា:

(ក). "ទីតាំងរងមានកំរិតដូច" មានន័យថា ទីតាំងរងដែលមានរង្វង់សញ្ញាមួយ (កំរិត ១) ឬទីតាំងរងដែលមានរង្វង់សញ្ញាពីរ (កំរិត ២) ។ ដូច្នេះ នៅពេលគិតទៅដល់គុណ

សម្បត្តិពាក់ពន្ធ័ដល់ទីតាំងរងមានវេជ្ជសញ្ញាពីរ ឬច្រើននៅក្នុងទីទាំងតែមួយ ដែលបានបកស្រាយក្នុងវិធានទី ៣ក នោះ លក្ខណៈពិសេសរបស់វាពាក់ពន្ធ័ដល់វត្ថុណាមួយនោះ ត្រូវតែអាចធ្វើបានដោយឈរលើមូលដ្ឋាន នៃអត្ថបទ នៃទីតាំងដែលមានវេជ្ជសញ្ញាមួយណាមួយនោះ ។ នៅពេលដែលទីតាំងរងមានវេជ្ជសញ្ញាមួយ ដែលមានភាពជាក់ច្បាស់បំផុតត្រូវបានជ្រើសយក ហើយនៅពេលទីតាំងរងនោះ អាចបំបែកទីតាំងរងបន្តទៅទៀតនោះ គេត្រូវតែគិតពិចារណាតែអត្ថបទ នៃទីតាំងរងដែលមានវេជ្ជសញ្ញាពីរ ដើម្បីសំរេចយកទីតាំងរងដែលមានវេជ្ជសញ្ញាពីរ ។

(ខ). ពាក្យថា "លើកលែងតែមានចែងនៅបរិបទដទៃ": គឺមានន័យលើកលែងតែកំណត់សំគាល់នៃផ្នែក ឬជំពូក មិនអាចយកមកប្រើបានចំពោះអត្ថបទ នៃទីតាំងរង ឬកំណត់សំគាល់នៃទីតាំងរង ។ ឧទាហរណ៍ នៅក្នុងជំពូកទី ៧១ នៅពេលដែលការដោះស្រាយចំពោះពាក្យ "PLATINUM" នៅក្នុងកំណត់សំគាល់ នៃជំពូកទី ៤ខ ខុសគ្នាពីពាក្យ "PLATINUM" នៅក្នុងកំនត់សំគាល់ទី ២ នៃទីតាំងរង ។ ដើម្បីបកស្រាយទីតាំងរងលេខ ៧១១០.១១ និង ៧១១០.១៩ គេត្រូវយកកំណត់សំគាល់ទីតាំងរងលេខ ២ មកអនុវត្ត រីឯកំណត់សំគាល់ទី ៤ខ នៃ ជំពូកមិនត្រូវយកមកគិតឡើយ ។

(III). វិសាលភាពទីតាំងរងដែលមានវេជ្ជសញ្ញាពីរ មិនត្រូវបានពង្រីកអោយហួសពីក្របខ័ណ្ឌ នៃទីតាំងរងដែលមានវេជ្ជសញ្ញាមួយ ដែលទីតាំងរងមានវេជ្ជសញ្ញាពីរត្រូវតែស្ថិតនៅ និង វិសាលភាពនៃទីតាំងដែលមានវេជ្ជសញ្ញាមួយ មិនត្រូវពង្រីកអោយហួសពីក្របខណ្ឌ័ នៃទីតាំង ដែលទីតាំងរងដែលមានវេជ្ជសញ្ញាមួយស្ថិតនៅ ។

២០០៧